សួស្តីឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ

HAPPY KHMER NEW YEAR

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អ៊ីម ឈុនលឹម
ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

សារជូនពរ
សូមគោរពជូន
ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អ៊ីម ឈុនលឹម ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់ !

ក្នុងវិកាសដ៏មហាពិភពក្តីប្ញកប្ញ ប្រកបដោយសេចក្តីសោមនស្សរីករាយ ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ខាងមុខនេះ: តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ ខ្ញុំបាទនិងភរិយា សូមជូននូវសព្វសាធុការពរដ៏ល្អ សិរីមង្គល វិបុលសុខ មហាប្រសើរ ជូន **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត** សូមទទួលបាននូវសុខភាពល្អហិបូរ: កម្លាំងកាយមាំមួន បញ្ញាញាណវាងវៃ ជន្មាយុយืนយូរ ដើម្បីអាចបំណែកជាមួយយោជនាជ្ញាកិបាលក្នុងការដឹកនាំប្រទេសជាតិវ៉ីកាន់ តែរឹងមាំ ឆ្ពោះទៅការអភិវឌ្ឍ ប្រកបដោយនិរន្តរភាព និងភាពសម្បូរសប្បាយរុងរឿង។

ឆ្លៀតក្នុងវិកាសដ៏ឧត្តុង្គឧត្តមនេះ: យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរពស្រឡាញ់ចំពោះវ:ភាពដ៏ឧត្តុង្គឧត្តមរបស់ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត** ជាមគ្គុរទេសក៍ដ៏ផ្ចើមមួយរូបក្នុងប្រវត្តិសាស្ត្រនៃក្រមប្រឹក្សាធម្មនុញ្ញដែលជាស្ថាប័នកំពូលរបស់ជាតិ តែងតែលះបង់កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី ក្នុងការបំពេញបេសកកម្ម ដ៏ឧត្តុង្គឧត្តមក្នុងបុព្វហេតុជាតិមាតុភូមិសម្រេចនូវសមិទ្ធផលដ៏ត្រចះត្រចង់ និងការអភិវឌ្ឍ។

ជាចុងក្រោយទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងតាងយោធពលខេមរភូមិន្ទទាំងមូល ខ្ញុំបាទនិងភរិយា សូមបួងសួងចំពោះគុណបុណ្យព្រះតនត្រ័យ និងវត្ថុស័ក្ដិសិទ្ធិទាំងឡាយក្នុងលោក មានទេវតាថ្នាំថ្មី ទេវតាថ៍ក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថ៍ក្សាការពារ និងប្រោះប្រាំនូវសព្វសាធុការពរដ៏ល្អ ជូន **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត** និង**លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណ: សុខ: ពល: កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អ៊ីម ឈុនលឹម ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពជំនន់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែមេឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០២៦
នាយឧត្តមសេនីយ៍ ជ្រៀ សីហា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

ទីស្នាក់ការមីន្ទ្រី សង្កាត់ទន្លេបាសាក ខណ្ឌឫស្សីកែ រាជធានីភ្នំពេញ ទូរស័ព្ទលេខ០២៣ ៨៨៣ ២៥៧៨ email: generalsec@mod.gov.kh